# វឌ្ឍនភាព នៃការផ្តល់បណ្ណសមធម៌ដល់អ្នកផ្ទុកមេរោគអេដស៍ នៅតាមសេវាព្យាបាលអ្នកជំងឺអេដស៍

PLHIV Registration
IDPoor

បង្ហាញដោយ វេជ្ជ. សំរិត សុវណ្ណរិទ្ធ
អនុប្រធាន
មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
Web: www.nchads.gov.kh

# មាតិកា

1. សង្ខេប ស្ថានភាពមេរោគអេដស៍/ជំងឺអេដស៍ នៅកម្ពុជា
2. ដំណើរការ និងវឌ្ឍនភាព នៃការផ្ដល់បណ្ណសមធម៌ ដល់អ្នកផ្ទុកមេរោគអេដស៍
3. បញ្ហាប្រឈម
4. សេចក្ដីសន្និដ្ឋាន និងជំហាន ដែលត្រូវអនុវត្តន៍បន្ត

# ១. សង្ខេបស្ថានភាពមេរោគអេដស៍/ជំងឺអេដស៍ នៅកម្ពុជា (ឆ្នាំ ២០២៤)

## ចំនួនអ្នកផ្ទុកមេរោគអេដស៍

| | |
|---|---|
| **Total** | **76 000** |
| Adults (15+years) | 75 000 |
| Women (15+ years) | 36 000 |
| Children (<15 years) | 1300 |

## ចំនួនអ្នកឆ្លងថ្មី នៃមេរោគអេដស៍

| | |
|---|---|
| **Total** | **1200** |
| Adults (15+ years) | 1200 |
| Children (<15 years) | <100 |

## ចំនួនអ្នកស្លាប់ដោយសារ ជំងឺអេដស៍

| | |
|---|---|
| **Total** | **1000** |
| Adults (15+ years) | 1000 |
| Children (<15 years) | <100 |

## ចំនួនអ្នកផ្ទុកមេរោគអេដស៍ ទទួលបានការព្យាបាល ART

| | |
|---|---|
| **Total** | **69 994** |
| Adults (15+ years) | 69 166 |
| Children (<15 years) | 828 |

Source: Cambodia 2025 HIV Estimates based on AEM-spectrum HIV Modelling

# ១. ចំនួនអ្នកផ្ទុកមេរោគអេដស៍សកម្ម ទទួលបានការព្យាបាល ART




Source: Progress Report, NCHADS

# ១. ចំនួនអ្នកផ្ទុកមេរោគអេដស៍ រកឃើញថ្មី បានចុះបញ្ជីទទួលការព្យាបាល ART (តាមឆ្នាំ)




Source: Progress Report, NCHADS

# ២. ដំណើរការ នៃការផ្តល់បណ្ណសមធម៌ ដល់អ្នកផ្ទុកមេរោគអេដស៍

អ្នកផ្ទុកមេរោគអេដស៍ ត្រូវបានទទួលស្គាល់ថា ជាក្រុមប្រជាជនងាយរងគ្រោះ ដែលត្រូវទទួលបានបណ្ណសមធម៌ តាមរយៈ ស.ជ.ណ. **លេខ ២១៣ សជណ.សស** ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១៩ ។

ដំណើរការចុះបញ្ជីផ្តល់បណ្ណសមធម៌ដល់អ្នកផ្ទុកមេរោគអេដស៍ ត្រូវបានអនុវត្តតាម **សេចក្តីណែនាំស្តីពីនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ ក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ លេខ ០១៤៥ ផក** ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២ ។

# ២. ដំណើរការ នៃការផ្តល់បណ្ណសមធម៌ ដល់អ្នកផ្ទុកមេរោគអេដស៍

បណ្ណសមធម៌សម្រាប់អ្នកផ្ទុកមេរោគអេដស៍ ត្រូវបានអនុញ្ញាត ឱ្យផ្តល់នៅតាមសេវាព្យាបាលអ្នកជំងឺអេដស៍ ដោយគោរពតាមលក្ខខ័ណ្ឌ៖

- ស្ម័គ្រចិត្តដោយគ្មានការបង្ខំ
- មានឈ្មោះក្នុងបញ្ជីព្យាបាលអ្នកជំងឺអេដស៍ នៅតាមសេវាព្យាបាល
- មានអត្តសញ្ញាណបណ្ណ ឬ សំបុត្រកំណើត ឬ លិខិតឆ្លងដែន
- មិនមានបណ្ណសមធម៌គ្រួសារ ចេញដោយឃុំ សង្កាត់

# ២. ដំណើរការ នៃការផ្តល់បណ្ណសមធម៌ ដល់អ្នកផ្ទុកមេរោគអេដស៍

## ឧបករណ៍ ចាំបាច់ សម្រាប់អនុវត្តន៍ការចុះឈ្មោះផ្តល់បណ្ណសមធម៌៖

- Internet connection
- Computer/Tablet, Color Printer, ក្រដាស A5 កំរាស់ 170mg

PLHIV Registration

IDPoor

## ដំណើរការចុះឈ្មោះផ្តល់បណ្ណមាន ៥ដំណាក់កាល ៖

- សម្ភាសន៍ និងបញ្ចូលពត៌មាន អ្នកជំងឺ
- ផ្ទៀងផ្ទាត់ ពត៌មានឡើងវិញដើម្បីឲ្យប្រាកដថាត្រឹមត្រូវ
- អនុម័ត ដើម្បីផ្តល់បណ្ណជូនបុគ្គលជាអ្នកផ្ទុកមេរោគអេដស៍
- បោះពុម្ពបណ្ណសមធម៌
- ចុះហត្ថលេខា និងត្រា ប្រធានមន្ទីរពេទ្យ



# ២. វឌ្ឍនភាព នៃការផ្ដល់បណ្ណសមធម៌ ដល់អ្នកផ្ទុកមេរោគអេដស៍

## ចំនួនអ្នកផ្ទុកមេរោគអេដស៍សកម្ម បានទទួលបណ្ណសមធម៌

គិតត្រឹមត្រីមាសទី៣ ឆ្នាំ ២០២៥ អ្នកផ្ទុកមេរោគអេដស៍សកម្ម បានទទួលបណ្ណសមធម៌ មានចំនួន **៥៣ ៨២១ នាក់ (៧៥%)** នៃអ្នកផ្ទុកមេរោគអេដស៍សកម្មកំពុងទទួល ART សរុប ចំនួន ៧១៧១៦ នាក់ ។




Source: Progress Report, NCHADS

# ២. វឌ្ឍនភាព នៃការផ្ដល់បណ្ណសមធម៌ ដល់អ្នកផ្ទុកមេរោគអេដស៍

## ចំនួនអ្នកផ្ទុកមេរោគអេដស៍សកម្ម បានទទួលបណ្ណសមធម៌ (តាមឆ្នាំ)




Source: Progress Report, NCHADS

# ២. វឌ្ឍនភាព នៃការផ្តល់បណ្ណាសមធម៌ ដល់អ្នកផ្ទុកមេរោគអេដស៍

## មន្ទីរពេទ្យ ដែលមានចំនួនអ្នកផ្ទុកមេរោគអេដស៍សកម្ម បានទទួលបណ្ណសមធម៌ តិចជាង ៧០%




Source: Progress Report, NCHADS

# ៣. បញ្ហាប្រឈម

- ការចុះបញ្ជីផ្តល់បណ្ណសមធម៌សម្រាប់អ្នកផ្ទុកមេរោគអេដស៍ មិនទាន់អាចអនុវត្តបាន នៅសេវាព្យាបាលជំងឺអេដស៍ នៃមន្ទីរពេទ្យព្រះកេតមាលា (១ ២៥៨ នាក់) មន្ទីរពេទ្យយោធាភូមិភាគ៥ (២១៤ នាក់) និងមន្ទីរពេទ្យកុមារអង្គរ (៦៧ នាក់)
- អ្នកផ្ទុកមេរោគអេដស៍មួយចំនួន មិនមានឯកសារបញ្ជាក់អត្តសញ្ញាណ ឬ នៅលាក់អត្តសញ្ញាណ
- សេវាព្យាបាលអ្នកជំងឺអេដស៍មួយចំនួន មានបញ្ហាកង្វះឧបករណ៍ សម្រាប់អនុវត្តការងារដូចជា Internet connections, computers, tablets, printers



Source: Progress Report, NCHADS

# ៨. សេចក្តីសន្និដ្ឋាន និងជំហាន ដែលត្រូវអនុវត្តន៏បន្ត

- ទោះបីជាមានបញ្ហាប្រឈមខ្លះៗ ការចុះបញ្ជីផ្តល់បណ្ណសមធម៌ សម្រាប់អ្នកផ្ទុកមេរោគអេដស៍ ត្រូវបានអនុវត្តន៍ដោយរលូន ហើយអត្រាអ្នកផ្ទុកមេរោគអេដស៍សកម្ម ទទួលបានបណ្ណសមធម៌ កើនឡើងដល់ ៧៥% គិតត្រឹមត្រីមាសទី៣ ឆ្នាំ២០២៥។
- មជ្ឈមណ្ឌលជាតិ៖
  - នឹងបន្តសហការជាមួយស្ថាប័ន និងអង្គភាព ពាក់ព័ន្ធ ដើម្បីបង្កើនការចុះបញ្ជីផ្តល់បណ្ណសមធម៌នេះ ជាពិសេស នៅតាមសេវាព្យាបាលអ្នកជំងឺអេដស៍ ដែលអត្រាអ្នកផ្ទុកមេរោគអេដស៍ ទទួលបានបណ្ណសមធម៌ នៅទាប
  - រៀបចំវាយតម្លៃអំពីការប្រើប្រាស់សេវាសុខាភិបាល និងការទទួលបានអត្ថប្រយោជន៍គាំពារសង្គម ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ ដែលមានបណ្ណសមធម៌
- សំណូមពរដល់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជួយសម្របសម្រួល ដោះស្រាយការចុះបញ្ជីបណ្ណសមធម៌សម្រាប់អ្នកផ្ទុកមេរោគអេដស៍ នៅសេវាព្យាបាលជំងឺអេដស៍នៃមន្ទីរពេទ្យយោធា



Source: Progress Report, NCHADS

# Acknowledgments

សូមអរគុណ !